**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ :....៥២...ភ.រ.ក

# សេចក្ដីសំរេច

## ស្ដីពី

## ការដាក់អោយប្រើប្រាស់បទដ្ឋានគំរូពណ៌ និងកំណត់សញ្ញាសំគាល់ សំរាប់អនុវត្តក្នុងប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លីនៅកម្ពុជា

---

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦៩៩ /០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីលិខិតអនុញ្ញាសាងសង់
- យោងមតិឯកភាពអង្គប្រជុំអន្តរក្រសួងនាថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៧
- យោងតាមការចាំបាច់របស់ក្រសួង ។

## សំរេច

**ប្រការ១** : ដាក់អោយប្រើប្រាស់ជាទូទៅនូវបទដ្ឋាន គំរូពណ៌ និងកំណត់សញ្ញាសំគាល់ សំរាប់អនុវត្តក្នុងប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លីនៅកម្ពុជា ដូចមានចែងក្នុងឧបសម្ព័ន្ធនៃសេចក្ដីសំរេចភ្ជាប់ជាមួយ ។

**ប្រការ២** : ការសិក្សាប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លីនៅកម្ពុជា ត្រូវគោរពតាមបទដ្ឋាននេះ ។

**ប្រការ៣** : សេចក្ដីសំរេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ២៨...ខែ...មិថុនា...ឆ្នាំ ២០០៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

អ៊ឹម ឈុនលឹម

<u>កន្លែងទទួល</u>
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងបរិស្ថាន
- គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធនៃក្រសួង ដ.ន.ស
- គ្រប់មន្ទីរ.ដ.ន.ស.ស.ខេត្ត ក្រុង - ដើម្បីអនុវត្តន៍-
- ឯកសារ-កាលប្បវត្តិ